**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**

## សេចក្តីថ្លែងការណ៍ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាថ្កោលទោសអំពើឈ្លានពានរបស់យោធាថៃមកលើដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សម្តែងការថ្កោលទោសយ៉ាងខ្លាំងក្លាចំពោះទង្វើឈ្លានពានដោយចេតនា និងខុសច្បាប់ ដែលបង្កឡើងដោយកងកម្លាំងប្រដាប់អាវុធនៃព្រះរាជាណាចក្រថៃ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥។ ទង្វើប្រកបដោយអវិភាព ដែលបានកើតឡើងនៅជិតប្រាសាទតាមាន់តូច ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី តំបន់មុំបី និងតំបន់ផ្សេងទៀតដែលស្ថិតនៅក្នុងព្រំដែនកម្ពុជាដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ គឺជាការរំលោភបំពានដោយផ្ទាល់លើអធិបតេយ្យរបស់កម្ពុជា និងជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ រួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិផងដែរ។

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការប្រកាសដូចតទៅ៖

១. ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើឈ្លានពានប្រដាប់ដោយអាវុធរបស់កងកម្លាំងយោធាថៃ ដែលបណ្តាលឱ្យមានការប្រយុទ្ធគ្នានិងបង្កផលប៉ះពាល់ទៅដល់សន្តិភាព និងស្ថិរភាពនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ទង្វើនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើអធិបតេយ្យរបស់កម្ពុជា គំរាមកំហែងដល់សន្តិភាពក្នុងតំបន់ និងរំលោភលើមាត្រា ២(៤) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលហាមឃាត់ការប្រើប្រាស់កម្លាំងប្រឆាំងនឹងបូរណភាពទឹកដីនៃរដ្ឋណាមួយ។

២. គូសបញ្ជាក់សាជាថ្មីពីសិទ្ធិការពារខ្លួនរបស់កម្ពុជា ស្របតាមមាត្រា ៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ កងយោធពលខេមរភូមិន្ទធ្វើសកម្មភាពប្រកបដោយវិជ្ជាជីវៈ និងអត់ធ្មត់បំផុតនៅក្នុងការអនុវត្តសិទ្ធិនេះ សំដៅការពារទឹកដីដ៏ពិសិដ្ឋ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

៣. សូមធ្វើការអះអាងថា តំបន់ជុំវិញប្រាសាទតាមាន់តូច ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី និងតំបន់មុំបី គឺស្ថិតនៅក្នុងទឹកដីកម្ពុជា ដូចដែលមានគូសបញ្ជាក់នៅក្នុងសន្ធិសញ្ញា ផែនទីដែលទទួលស្គាល់ជាអន្តរជាតិ និងការកំណត់តាមផ្លូវច្បាប់អន្តរជាតិពាក់ព័ន្ធ។ វត្តមានយោធាកម្ពុជានៅក្នុងតំបន់ទាំងអស់នេះ គឺស្របតាមច្បាប់ និងស្ថិតក្នុងសិទ្ធិអធិបតេយ្យពេញលេញរបស់កម្ពុជា។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

៤. ក្នុងកាលៈទេសៈដ៏សំខាន់នេះ សូមប្រកាសជាឱឡារិកគាំទ្រយ៉ាងពេញទំហឹងចំពោះភាពជាអ្នកដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយចក្ខុវិស័យរបស់**សម្តេចតេជោ ប្រធានព្រឹទ្ធសភា** ស្ថាបនិកសន្តិភាពរបស់មាតុភូមិកម្ពុជា និងភាពជាអ្នកដឹកនាំប្រកបដោយភាពស្វាហាប់និងម៉ឺងម៉ាត់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៅចំពោះមុខអំពើឈ្លានពានដ៏គឃ្លើននេះ។ អនុសាសន៍ដឹកនាំរបស់ **សម្តេច** ទាំងទ្វេ ពិតជាមានភាពចាំបាច់បំផុតនិងមិនអាចខ្វះបាន នៅក្នុងបុព្វហេតុការការពារអធិបតេយ្យជាតិ ថែរក្សាសន្តិភាព ព្រមទាំងការពារជំហរដ៏ត្រឹមត្រូវរបស់កម្ពុជានៅក្នុងសហគមន៍អន្តរជាតិ។

៥. សូមសម្តែងនូវការគោរពនិងគាំទ្រយ៉ាងពេញទំហឹងចំពោះភាពអង់អាចក្លាហាន និងបទវិន័យរបស់កងយោធពលខេមរភូមិន្ទ ដែលបានបំពេញកាតព្វកិច្ចស្របតាមច្បាប់រដ្ឋធម្មនុញ្ញប្រកបដោយភាពមោះមុតនិងកិត្តិយសបំផុត នៅចំពោះមុខការឈ្លានពានពីបរទេស។

៦. អំពាវនាវដល់សហគមន៍អន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិ អាស៊ាន និងប្រទេសដែលស្រលាញ់សន្តិភាព សូមចាត់វិធានការជាបន្ទាន់និងដាច់ខាត ដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានដ៏ធ្ងន់ធ្ងរនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
Nation – Religion - King

SENATE

# Statement by the Senate of the Kingdom of Cambodia Condemning the Thai Military's Aggression Against the Sovereign Territory of the Kingdom of Cambodia

The Senate of the Kingdom of Cambodia expresses its strongest condemnation of the intentional and illicit military aggression perpetrated by the armed forces of the Kingdom of Thailand on 24 July 2025. This hostile act carried out near the sacred temples of Ta Mone Thom, Ta Mone Touch, Ta Krabey, Mum Bey, and other locations situated well within Cambodia's internationally recognized borders, constitutes a direct violation of Cambodia's sovereignty and a grave breach of international law, including the Charter of the United Nations.

The Senate hereby declares the following:

1. Unequivocally condemns the armed incursion by Thai military forces, which resulted in clashes and endangered peace and stability along the Cambodia–Thailand border. This act constitutes a serious violation of Cambodia's sovereignty, a threat to regional peace, and a breach of Article 2(4) of the UN Charter prohibiting the use of force against the territorial integrity of any state.
2. Reaffirms Cambodia's inherent right to self-defense under Article 51 of the UN Charter. The Royal Cambodian Armed Forces acted with professionalism and restraint in exercising this right, defending sacred national territory and the safety of Cambodian citizens.
3. Asserts that the areas surrounding Ta Mone Thom, Ta Mone Touch, Ta Krabey temples and Mom Bey lie well within Cambodian territory, as confirmed by historical treaties, internationally recognized maps, and relevant international

Vimeanrath Chamkarmon, Preah Norodom Boulevard, Phnom Penh, Kingdom of Cambodia
Tel : (855 23) 211 441, 211 442, 211 443 Fax : (855 23) 211 446, E-mail : secretariat@senate.gov.kh

legal determinations. Cambodia's military presence in these areas is lawful and fully within its sovereign rights.

4. In this pivotal moment, declares its profound support for the wise and visionary leadership of Samdech Techo, the President of the Senate, the founder of Peace of the Cambodian Motherland, and for the dynamic and resolute leadership of the Prime Minister in confronting this grave act of aggression. Their unwavering guidance is indispensable to the protection of the nation's sovereignty, the maintenance of peace, and the safeguarding of Cambodia's rightful standing within the international community.
5. Expresses its full support and respect for the bravery and discipline of the Royal Cambodian Armed Forces, who have fulfilled their constitutional duty with courage and honor in the face of external aggression.
6. Calls upon the international community including the United Nations, ASEAN, and all peace-loving nations to take urgent and decisive action in response to this grave violation.

Phnom Penh, 24 July 2025